00346120

E72/1


ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 30 / 06 / 2009
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy


នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/
ថ្ងៃដាក់: ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩
ភាគីអ្នកដាក់: ការិយាល័យសហព្រះរាជអាជ្ញា
ភាសាដើម: ខ្មែរ
ប្រភេទឯកសារដែលស្នើឡើង: សាធារណៈ

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន សុំឲ្យចេញសេចក្ដីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោស**

---

<u>អ្នកដាក់ឯកសារ:</u>

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED


ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 02 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy


<u>អ្នកទទួលឯកសារ:</u>

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖**
លោក Karim A.A. KHAN
កញ្ញា ទី ស្រីនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
កញ្ញា Silke STUDZINSKY

**មេធាវីជនជាប់ចោទ៖**
លោក ការ សាវុត្ថ
លោក François ROUX

00346121

E72/1

*សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

## ១.សេចក្តីផ្តើម

១. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម២ (“ភាគីដាក់ពាក្យសុំ”) បានស្នើសុំឱ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស (“សំណើ”)[1] ។

## ២.សេចក្តីសង្ខេប

២. នៅក្នុងច្បាប់ និងវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជានៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងហាមឃាត់ដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោសនោះទេ។ ម្យ៉ាងទៀត នៅក្នុងការអនុវត្តរបស់តុលាការ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោសផងដែរ។

## ៣.សេចក្តីសន្និដ្ឋាន

៣. សហព្រះរាជអាជ្ញា មិនមានការយល់ទាស់ចំពោះសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនេះទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង គួរធ្វើការពិចារណាសំណើនេះ ដែលមាននៅក្នុងសំណុំរឿង

[1] *ករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច*, ក្រុម១ និង២ -- សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស, សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ (អ.ប.ជ E72), ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ ។

00346122

E72/1

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

លេខ ០០១ និង លេខ ០០២ ហើយវាជាការចាំបាច់ចំពោះសេចក្ដីសន្និដ្ឋាននេះ ដើម្បីឱ្យវាមានភាពរលូនទៅនឹងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩

សហព្រះរាជអាជ្ញា

CO-PROSECUTORS CO-PROCUREURS

លោកស្រី ជា លាង　　　លោក Robert PETIT